គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ខុមហ្វ្រែល COMFREL

ទីស្នាក់ការកណ្ដាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**
BOARD OF DIRECTORS

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារ៉ា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សីន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ១២/០៩ គ.ប.ស.យ/អ.ក

# សេចក្ដីប្រកាសព័ត៌មាន

## ស្ដីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត បាត់ដំបង

*ភ្នំពេញ, ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៩០នាក់ មកពីស្រុកទាំង៩ នៅក្នុងខេត្តបាត់ដំបង និងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ២៧% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តបាត់ដំបងនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៩។

សមាជិកក្រុមប្រឹក្សាខេត្តបាត់ដំបង ឯកឧត្តម ជា ជីវ មានប្រសាសន៍ថា សិក្ខាសាលានេះ បងប្អូនបានផ្ដល់គំនិត និងយោបល់ដែលត្រូវការនៅក្នុងសហគមន៍របស់ខ្លួនសំរាប់អោយតំណាងរបស់ខ្លួនអនុវត្ត ហើយឯកឧត្តម នឹងពាំនាំសំណើរបស់ប្រជាពលរដ្ឋដើម្បីយកទៅដាក់នៅក្រុមប្រឹក្សាខេត្ត ជាពិសេសទៅលើចំនុចជាអាទិភាព ។

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តបាត់ដំបងដូចខាងក្រោមៈ

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តបាត់ដំបងរួមមានៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០នៅក្នុងខេត្ត បាត់ដំបង** |
|---|
| ១) ស្នើសុំរកទីផ្សារដើម្បីលក់ផលិតផលកសិកម្ម នៅក្នុងស្រុក និងក្រៅស្រុក ដូចជា ស្រូវ ពោត ដំឡូងមី ល្ង បន្លែផ្លែឈើ...។ល។ ជាពិសេសសុំឱ្យតម្លៃស្រូវ ១គីឡូក្រាម ស្មើនឹងតម្លៃ ៤០% នៃតម្លៃសាំង ១លីត្រ ចាប់ពី ខែ តុលា ឆ្នាំ២០០៩ នេះតទៅ។ |
| ២) ស្នើសុំឱ្យបង្កើតមជ្ឈមណ្ឌលប្រឹក្សាយោបល់ និងដោះស្រាយបញ្ហាលើដំណាំកសិកម្ម និងសត្វ ចំនួន ១កន្លែង ក្នុងស្រុកមោងឫស្សីអោយហើយនៅចុងឆ្នាំ ២០១២ តទៅ។ |

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្ដែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ៣) សុំឱ្យមានការកំណត់តម្លៃថយន្តឈ្នួល ដឹកនាំអ្នកដំណើរ (សំរាប់ថ្ងៃបុណ្យឱ្យដូចថ្ងៃធម្មតា) ។ សុំឱ្យមានកំណត់តម្លៃ ប្រេងសាំង ម៉ាស៊ូត និងជីគីមី ឱ្យសមាមាត្រ ទៅនឹងប្រទេសជិតខាង ចាប់ពីខែ សីហាឆ្នាំ២០០៩ នេះតទៅ។ |
| ៤) សុំបង្កើតរោងចក្រក្រចៅ នៅក្នុងស្រុកឯកភ្នំ និងរោងចក្រទឹកក្រូច នៅក្នុងក្រុងបាត់ដំបងអោយដំណើរការឡើងវិញ របស់ខេត្ត បាត់ដំបង ឱ្យហើយនៅចុង ឆ្នាំ២០១១។ សុំបង្កើតរោងចក្រកាត់ដេរ ចំនួន ១កន្លែង នៅក្នុងក្រុងបាត់ដំបង ខេត្តបាត់ដំបង ចាប់ផ្តើម ក្នុងឆ្នាំ ២០១០ ដល់ ឆ្នាំ២០១១។ |
| ៥) សុំអោយបង្កើតសហគមន៍នេសាទ និង សហគមន៍ព្រៃឈើ នៅស្រុកមោងឬស្សី និងស្រុកគាស់ក្រឡ ឱ្យបានក្នុង អំឡុង ឆ្នាំ២០០៩ រហូតដល់ចុងឆ្នាំ ២០១០ និងអនុវត្តតទៅ [រដ្ឋាភិបាលដឹកនាំបង្កើតសហគមន៍ រួចទើបប្រគល់អោយប្រជាពលរដ្ឋ]។ |
| ៦) សុំរដ្ឋាភិបាលកំណត់ជាគោលការណ៍ឱ្យច្បាស់ ជំរុញ និងលើកទឹកចិត្ត ស្ត្រី ចូលរួមក្នុងថ្នាក់ដឹកនាំ ថ្នាក់ភូមិ ឃុំ ស្រុក ខេត្ត និងជាតិ ឱ្យបាន ៤០% ក្នុងខេត្តបាត់ដំបង ចាប់ពីឆ្នាំ២០១០ នេះតទៅ។ |
| ៧) ស្នើសុំឱ្យរដ្ឋាភិបាល បោសសំអាតមីន ក្នុងស្រុកគាស់ក្រឡ ឃុំឆ្នាល់មាន់ ភូមិឆ្លាក ដើម្បីផ្តល់ដីសម្បទានសង្គមកិច្ច ដល់ប្រជាពលរដ្ឋ ក្រីក្រ ចំនួន ៥ហិចតា ក្នុងមួយគ្រួសារ អោយបានគ្រប់គ្រួសារ ដើម្បីធ្វើកសិកម្មក្នុង ស្រុកគាស់ក្រឡ ចាប់ពី ខែសីហា ឆ្នាំ២០០៩ នេះតទៅ។ |
| ៨) សុំឱ្យរដ្ឋាភិបាលមានការផ្តល់ប្រាក់កម្ចី ដល់ប្រជាពលរដ្ឋ ដើម្បីយកទៅធ្វើកសិកម្មក្នុងអត្រាការប្រាក់ទាប ប្រហែល ១% ក្នុងមួយឆ្នាំ នៅក្នុងខេត្តបាត់ដំបង ចាប់ពីចុងឆ្នាំ២០០៩ នេះតទៅ។ |
| ៩) សុំសាងសង់ស្ពានថ្មីមួយ (ជំនួសស្ពានចាស់) ធ្វើពីបេតុង មានបណ្តោយប្រវែង ១២មែត្រ ទទឹង ៨មែត្រ ក្នុងភូមិ ខ្នាចរមាស ឃុំខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង ចាប់ផ្តើមពីចុងឆ្នាំ២០០៩ ដល់ចុងឆ្នាំ២០១០។ |
| ១០) សុំឱ្យសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ឱ្យបាននៅដើមឆ្នាំ២០១០ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យអង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករមកពីស្រុក រតនៈមណ្ឌល ស្រុកបវេល ស្រុកថ្មគោល ស្រុកបាណន់ ស្រុកគាស់ក្រឡ ស្រុកមោងឫស្សី ស្រុកឯកភ្នំ ស្រុកសង្កែ និង ក្រុងបាត់ដំបង នៅក្នុងខេត្តបាត់ដំបង។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាម មណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨

២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន

៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ដែលអាច ឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា /គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*


- លោក **ចំនួ ជាវិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦